# គណៈកម្មាធិការព្រំដែនកម្ពុជា

សមាគម មិនជាប់ពាក់ព័ន្ធ នឹង គណៈបក្ស នយោបាយ

Comité des Frontières du Cambodge ( C F C )

Cambodia's Border Committee ( C B C )

ASSOCIATION NON APPARENTEE AU PARTI POLITIQUE ASSOCIATION UNAFFILIATED TO A POLITICAL PARTY

CFC/CBC 241010 K-F

# សេចក្ដីប្រកាស នៃ គណៈកម្មាធិការព្រំដែនកម្ពុជា

## ឱកាសខួបទី១៩ នៃកិច្ចព្រមព្រៀងសន្តិភាព នាក្រុងប៉ារីស ឆ្នាំ១៩៩១ ស្ដីពីកម្ពុជា

*ថ្លែងដោយ លោក **ស៊ាន-ប៉េងសែ** នៅថ្ងៃទី២៤ តុលា ២០១០*

-----

***បងប្អូនរួមជាតិ និងមិត្ត ជាទីគោរព***

យើងមកជួបជុំគ្នា នាថ្ងៃនេះ នៅ"លាននៃសិទ្ធិមនុស្ស"នៃទីក្រុងប៉ារីស ដើម្បីស្រែកប្រាប់សកលលោក នូវសេចក្ដីឈឺចាប់ និងកំហឹងរបស់យើង ចំពោះពួកអ្នករំលោភ កិច្ចព្រមព្រៀងសន្តិភាព នាក្រុងប៉ារីស ឆ្នាំ១៩៩១ ស្ដីពីកម្ពុជា ជាទីស្រឡាញ់របស់យើង ។ សំរែករបស់យើងនៅទីនេះ ធ្វើឡើង មិនត្រឹមតែក្នុងនាមយើងផ្ទាល់ខ្លួនទេ គឺធ្វើក្នុងនាម អ្នកស្នេហាជាតិ និងប្រជាជនខ្មែរទាំងអស់ នៅក្នុងស្រុកដែរ ដែលគ្មានមិនអាចធ្វើបាតុកម្មនេះបាន ។

កិច្ចព្រមព្រៀងក្រុងប៉ារីសនេះ មានគោលដៅច្បាស់ គឺផ្ដល់សន្តិភាពឱ្យកម្ពុជា និងសេរីភាពឱ្យប្រជាជនខ្មែរ ។ ប៉ុន្តែ វៀតណាម និងពួកខ្មែរចូលដៃជាមួយគេ - ដែលបានក្បត់សេចក្ដីសង្ឃឹម នៃប្រជាជនខ្លួន និងប្រយោជន៍នៃមាតុភូមិរបស់ខ្លួន - បានសំរេចចិត្ត បន្តនយាបាយគ្របសង្កត់ និងធ្វើសម្ពាតគ្រប់យ៉ាង មកលើស្រុកយើង និងប្រឆាំងនិងប្រជាជនយើង ជានិច្ច។

កិច្ចព្រមព្រៀងក្រុងប៉ារីស បានដាក់កំហិត ឱ្យអ្នកបានចុះហត្ថលេខាទាំងអស់គ្នា "ប្រកាន់ ថែរក្សា និងការពារ ឯករាជ្យ អធិបតេយ្យ បូរណភាពដែនដី ភាពមិនអាចរំលោភបានលើដែនដីកម្ពុជា អព្យាក្រឹតភាព និងឯកភាពនៃជាតិខ្មែរ ។ ប៉ុន្តែ វៀតណាម នៅតែបន្តនយោបាយវាតទីរបស់វា ដោយនៅតែបន្ត ការកាន់កាប់ទឹកដី សមុទ្រ និងកោះខ្មែរ ព្រមទាំងបញ្ជូនបញ្ចូលពួកយួនអាណានិគម បន្ថែមទៀត ហើយឱ្យខ្មែរទទួល"សហប្រតិបត្តិការ"របស់វា ទាំងក្នុងនិស្ស័យប៉ូលីស សន្តិសុខ យោធា ការពារជាតិ រដ្ឋបាល ច្បាប់-តុលាការទាំងអស់ ជាមួយហ៊ុន-សែន និង"បក្សប្រជាជនកម្ពុជា"របស់គាត់ ។

កិច្ចព្រមព្រៀងក្រុងប៉ារីស មានគោលដៅ ឱ្យកើតមានការជានាគ្នា រវាងខ្មែរនិងខ្មែរ និងឱ្យប្រជាជនខ្មែរមានសិទ្ធិ សំរេចជោគវាសនាខ្លួន ដោយខ្លួនឯង ។ ការជានាគ្នារវាងខ្មែរ នឹងកើតមានបាន លុះត្រាតែមានយុត្តិធម៌លទ្ធិប្រជាធិបតេយ្យ និង ការលើកដំកើងជាតិ ដំកើងប្រជាជនខ្មែរជាថ្មី នៅក្នុងស្រុក ។ ប៉ុន្តែ ហ៊ុន-សែន និង"បក្សប្រជាជនកម្ពុជា"របស់គាត់ ដែលបានក្ដោបក្ដាប់អំណាចផ្ដាច់ការគ្រប់កន្លែង បានបង្ខំឱ្យខ្មែរទាំងអស់ ទទួល

យក"សន្តិភាព"របស់ពួកខ្លួន ដែលកើតពីការកំទេចកម្លាំងសកម្មទាំងអស់ របស់ជាតិ និងការសង្កត់សង្កីនពលរដ្ឋខ្មែរ ឱ្យលុតជង្គង់ នៅក្រោមការជិះជាន់របស់ពួកខ្លួន ដោយមានការជួយជំរុញ និងការគាំទ្រ ពីវៀតណាមផង ។

កិច្ចព្រមព្រៀងក្រុងប៉ារីស បានបញ្ជាឱ្យមាន ការការពារសិទ្ធិមនុស្ស នៅកម្ពុជា និងការរារាំងមិនឱ្យការប្រព្រឹត្តនយោបាយក្នុងអតិតកាល កើតមានវិញបាន។ ប៉ុន្តែ ហ៊ុន-សែន និង"បក្សប្រជាជនកម្ពុជា" មានតែការធ្វើប្រជាភិថុតិ ជាមួយគ្នានិងការភរកុហក់ ការកំចាត់យ៉ាងឃោរឃៅ លើអ្នកជំទាស់នយោបាយ និងអ្នកតវ៉ាផ្សេងៗទាំងអស់ ការជិរីតប្រវិញពុករលួយ និងការប្រព្រឹត្តរំលោភអំណាច ដើម្បីគាបប្រជាពលរដ្ឋ នៅក្នុងភាពល្ងិតល្ងង់ អំពីសិទ្ធិរបស់ខ្លួន នៅក្នុងការភ័យខ្លាច មិនហ៊ានបញ្ចេញសម្លេងតវ៉ាអ្វី និងឱ្យដាក់ខ្លួនចុះចាញ់គេ យ៉ាងថោកទាបបំផុត ។

កិច្ចព្រមព្រៀងក្រុងប៉ារីស បានសំរេចឱ្យអ្នកបានចុះហត្ថលេខាទាំងអស់ ជួយស្ថាបនាកម្ពុជាជាថ្មី គឺថាជួយស្តារឡើងវិញ នូវជីវភាពនៃប្រជាជនខ្មែរ ។ ប៉ុន្តែ ការបំផ្លាញសម្បត្តិជាតិខ្មែរ ដែលផ្តើមកើតមានក្នុងសម័យប៉ុល-ពតត្រូវបានកើនឡើង១០០ដងលើសមុនទៀត នៅក្នុងរបប ហ៊ុន-សែន និង"បក្សប្រជាជនកម្ពុជា" ។ ម្យ៉ាង ទៀតទោះជាកម្ពុជាបានជំនួយអន្តរជាតិ រាប់ពាន់លានដុល្លារក្តី ក៏របបនេះគ្មានបានបង្កើតអ្វីទាំងអស់ សំរាប់លើកកំពស់លក្ខខ័ណ្ឌជីវភាព របស់ប្រជាជនដែរ ។ អ្វីៗទាំងអស់ ត្រូវបានសាងសង់ ដោយអ្នកវិនិយោគបរទេសទាំងអស់ដើម្បីប្រយោជន៍ផ្ទាល់របស់គេ ។ ជំនួយអន្តរជាតិ ដែលបានមក គឺសំរាប់តែបំប៉នធនធាន របស់ហ៊ុន-សែនគ្រួសារគាត់ និងសមមិត្តរបស់គាត់ប៉ុណ្ណោះ។ រឿងដែលហៅថា"នយោបាយប្រយុទ្ធ កាត់បន្ថយភាពក្រីក្រ" វាជារឿងភរកុហក់មួយ យ៉ាងគ្រោតគ្រាតបំផុត ហើយភាពក្រតោកយ៉ាក នៃប្រជាជនខ្មែរ វាកាន់តែរីករាល យ៉ាងវេទនាខ្លាំងឡើងៗ ។

*បងប្អូនរួមជាតិ និងមិត្ត ជាទីគោរព*

ការដែលយើងស្រែកអំពាវនាវ នាថ្ងៃនេះទៀត សូមឱ្យសហគមអន្តរជាតិ ជំរុញឱ្យមាន ការគោរព និងការអនុវត្តន៍ យ៉ាងម៉ត់ចត់បំផុត នូវកិច្ចព្រមព្រៀងក្រុងប៉ារីសនេះ គឺពីព្រោះប្រជាជនខ្មែរ រស់នៅក្នុងអសន្តិសុខគ្រប់ប្រភេទ និងជាអចិន្ត្រៃយ៍... គឺវាគ្មានសន្តិភាព ដល់ស្រុកខ្មែរ និងដល់ប្រជាជនខ្មែរទេ... គឺវាដូចជាគេនៅបន្តសង្គ្រាម តទៅទៀត ។ ជាតិសាសន៍យើង ស្ថិតនៅមុខគ្រោះថ្នាក់ដល់ជីវិត ជានិច្ច ។

ហើយយើងស្រែកអំពាវនាវ ដល់ជនជាតិខ្មែរគ្រប់រូប នៅគ្រប់ទីសទីផងដែរ ឱ្យងើបរួមគ្នាឡើង ប្រយុទ្ធការពារមាតុភូមិយើង ។ យើងនឹងមានជោគជ័យ មិនខាន ។

ជយោ ប្រជាជនខ្មែរ !
ជយោ ស្រុកខ្មែរ !

---------

## Déclaration du CFC à l'occasion du 19e anniversaire des Accords de Paix de Paris de 1991 sur le Cambodge

*(Prononcée par M. SEAN Pengsè - le 24 octobre 2010)*

***Chers Compatriotes, Chers Amis,***

Nous sommes réunis aujourd'hui en cette Place des Droits de l'Homme pour exprimer au monde nos souffrances et nos colères contre ceux qui continuent à violer impunément les Accords de Paix de Paris de 1991 sur le Cambodge, notre cher pays. Nous le faisons, non seulement en nos propres noms, mais aussi au nom de tous les patriotes khmers au Cambodge et au nom du peuple khmer tout entier qui ne peuvent se manifester.

Les Accords de Paris ont voulu rétablir la paix au Cambodge et la liberté du peuple khmer. Mais le Vietnam communiste et ses complices khmers - qui ont trahi l'espoir de leur peuple et les intérêts de leur patrie - ont décidé de poursuivre leurs domination et pressions de tous genres dans notre pays et contre notre peuple.

Les Accords de Paris ont engagé toutes les Parties signataires à « *maintenir, préserver et défendre la souveraineté, l'indépendance, l'intégrité et l'inviolabilité territoriales, la neutralité et l'unité nationale du Cambodge…* » Mais Hanoi poursuit toujours ses visées expansionnistes en continuant son occupation des territoires khmers (terrestres et maritimes), l'envoi au Cambodge de ses colons protégés et le renforcement de ses « coopérations » policières, militaires, administratives et juridiques avec Hun Sen et son parti PPC.

Les Accords de Paris tiennent à « *promouvoir la réconciliation nationale et assurer au peuple cambodgien l'exercice de son droit à l'autodétermination…* ». Or, il ne peut avoir de vraie réconciliation sans le respect de la justice et de la démocratie, et sans aucun redressement de la vie nationale, du peuple complètement asservi durant ces trois dernières décennies. Le PPC, qui se cramponne au pouvoir sans partage, tient à imposer sa «paix» par l'élimination radicale des forces vives du pays, et par mettre les citoyens à genoux devant son implacable domination, encouragée et soutenue en cela par Hanoi.

Les Accords de Paris ordonnent d'« *assurer la protection des droits de l'homme et le non-retour à la politique et aux pratiques du passé* ». Ces « pratiques du passé » ne concernent pas seulement celle des polpotistes, mais aussi celles des autres régimes khmers. Mais, Hun Sen et son PPC imposent sa démagogie, ses mensonges, sa répression brutale des opposants et des mécontents, la corruption et les agissements arbitraires de leurs agents, pour réduire tout le peuple dans l'ignorance de ses droits, la peur, le silence et la soumission la plus dégradante.

Les Accords de Paris ont tenu à *« aider à la reconstruction du Cambodge* », c'est-à-dire à restaurer le bien-être du peuple khmer. Mais, la destruction des richesses du pays, commencée par Pol Pot, a augmenté au centuple avec le régime Hun Sen/PPC. Malgré les milliards de dollars d'aide internationale, ce régime n'a rien créé pour l'amélioration des conditions de vie de notre peuple. Tout est fait par des investissements des étrangers pour leurs propres intérêts. L'aide internationale sert surtout à engraisser Hun Sen, sa famille et son clan. La soi-disant « politique de lutte contre la pauvreté » n'a jamais été et n'est qu'un mensonge grossier : la pauvreté est partout et de plus en plus atroce.

***Chers Compatriotes, Chers Amis,***

Si nous continuons à faire appel à la Communauté internationale à œuvrer pour une application scrupuleuse de ces Accords de Paris sur le Cambodge, c'est parce que les Khmers vivent toujours dans une insécurité totale et permanente, c'est parce qu'il n'ya pas de paix pour le Cambodge et son peuple, comme si l'état de guerre doit rester volontairement maintenu et imposé à tout le pays. Notre Nation est en danger de mort !

Et aussi, pour appeler tous les Khmers à se lever ensemble et partout pour défendre leur Mère-Patrie. Nous vaincrons.

Vive le Peuple Khmer !
Vive le Cambodge !

---------